# ស្រឡាញ់បង ធ្វើឱយបងខូចចិត្ត

ចាំអារម្មស្នេហក្នុងចិត្តទេ?

បងឬមាសមេជាអ្នកភ្លេច

ពេលចួបបងហេតុអ្វីអូនគេច?

បងធ្វើដូចម្ដេចទើបដូចដើម?។

អារម្មស្រឡាញ់ប្រាប់បងថា

តាមល្បងជីវាជាដង្ហើម

តែមិនស្រួលដូចកាលចាប់ផ្ដើម

មាសស្រស់ថ្ងៃថ្មើមមិនខ្វល់ខ្វាយ។

ឬអូនភ្លេចថាអូនស្នេហបង?

ឬភ្លេចចំណងយើងពីរកាយ?

អនុស្សាវរីយយើងទាំងឡាយ

ធ្លាប់សើចសប្បាយម្ដេចបាត់បង់។

អូនដឹងថាអូនធ្វើអ្វីទេ?

បងដឹងមាសមេក៏មិនចង់

បើមានស្គាំស្គងប្រាប់តាមត្រង់

កុំចាំក្រៀមខ្វង់ទើបស្រោចទឹក។

ធ្វើអ្វីឱយបងសប្បាយចិត្ត

បានទេវរមិត្រ? បើមិននឹក

ស្រឡាញ់គ្នាចប់លែងរំឭក

បងផ្សងសូមផឹកទឹកនេត្រា។

អូនលែងស្រឡាញ់ជួសដោយស្អប់

ទើបត្រូវបញ្ចប់ដោយខ្លោចផ្សា

មិនអាចឱយបងសុខចិន្ដា

ខ្លាចនៅស្នេហាមិនអាចចប់៕

សៅរ, ២៣:០០-២៣:២១, ០៥/០៤/២០១៣